# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# ក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ

## ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

## សីហា ២០១៥

## បុព្វកថា

បច្ចុប្បន្ន ការប្រែប្រួលអាកាសធាតុត្រូវបានគេទទួលស្គាល់យ៉ាងពេញលេញថា ជាបញ្ហាប្រឈមដ៏ចំបងមួយចំពោះការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៅបណ្តាទសវត្សរ៍ខាងមុខ។ នៅប្រទេសកម្ពុជា បញ្ហាប្រឈមនេះ មានសភាពធ្ងន់ធ្ងរ ហើយកម្ពុជាត្រូវបានគេចាត់ថ្នាក់ជាប្រទេសដែលងាយរងគ្រោះបំផុតក្នុងចំណោមប្រទេសទាំងដប់នៅលើពិភពលោក និងងាយរងគ្រោះបំផុតក្នុងចំណោមប្រទេសចំនួនបីនៅក្នុងតំបន់អាស៊ី។

រាជរដ្ឋាភិបាលកម្ពុជាបានដាក់បញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយអភិវឌ្ឍន៍ តាមរយៈការប្រកាសដាក់ឱ្យប្រើប្រាស់នូវផែនការយុទ្ធសាស្ត្រឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុកម្ពុជានៅចុងឆ្នាំ២០១៣ និងការដាក់បញ្ចូលការប្រែប្រួលអាកាសធាតុជាបញ្ហាដែលមានចរិតអន្តរវិស័យទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨។ ក្រសួង-ស្ថាប័នចំនួនប្រាំបួនបានបញ្ចប់ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងផែនការសកម្មភាពតាមវិស័យរបស់ខ្លួន ហើយត្រឹមចុងឆ្នាំ២០១៥ ក្រសួង-ស្ថាប័នសរុបទាំងអស់ចំនួនដប់បួននឹងបញ្ចប់ការរៀបចំផែនការនេះ។

ប៉ុន្តែការងាររៀបចំផែនការយុទ្ធសាស្ត្រដ៏មានសារៈសំខាន់នេះ អាចនឹងចេញជាលទ្ធផលបានលុះត្រាតែមានធនធានគាំទ្រសមស្រប។ ហេតុផលនេះហើយ ដែលជំរុញឱ្យប្រទេសកម្ពុជាផ្តួចផ្តើមគំនិតរៀបចំក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុនេះឡើង សំដៅកំណត់នូវធនធានហិរញ្ញប្បទានអាកាសធាតុនាពេលបច្ចុប្បន្ន និងនិន្នាការនានាសម្រាប់រយៈពេលពីប្រាំឆ្នាំទៅដប់ឆ្នាំខាងមុខ ហើយប្រើប្រាស់ការប៉ាន់ស្មានទាំងនេះដើម្បីស្នើឡើងនូវតម្លៃចំណាយដែលមានភាពប្រាកដនិយម សម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ក្របខ័ណ្ឌនេះផ្តល់ការប៉ាន់ស្មានដំបូងនៃផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុលើសេដ្ឋកិច្ច និងការវិភាគ ថាតើការវិនិយោគវៃឆ្លាតខាងអាកាសធាតុអាចជួយកាត់បន្ថយផលប៉ះពាល់ទាំងអស់នេះបានដោយរបៀបណា។

ជាចុងក្រោយ ក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុផ្តល់នូវការណែនាំអំពីជំហានបន្តដើម្បីកែលម្អការកៀរគរ និងគ្រប់គ្រងហិរញ្ញប្បទានអាកាសធាតុ ទាំងពីប្រភពក្នុងស្រុកទាំងពីប្រភពអន្តរជាតិ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ អនុក្រុមការងារហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុនៃក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុដែលបានដឹកនាំការងារជាមួយអន្តរក្រសួងនានា ក៏ដូចជាសហគមន៍អឺរ៉ុប រដ្ឋាភិបាលស៊ុយអែត និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិចំពោះការគាំទ្រផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ។

ក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុនេះ ជាផែនទីបង្ហាញផ្លូវសម្រាប់ក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា ប៉ុន្តែនេះគ្រាន់តែជាដំណាក់កាលដំបូងក្នុងដំណើរការកសាងក្របខណ្ឌហិរញ្ញប្បទានអាកាសធាតុមួយនៅកម្ពុជាដែលមានភាពទុកចិត្តប្រកបដោយការទាក់ទាញ និងមានតម្លាភាព។

ខ្ញុំមានជំនឿយ៉ាងមុតមាំថា គ្រប់ភាគីពាក់ព័ន្ធទាំងអស់នឹងចាប់ផ្តើមអនុវត្តសកម្មភាពដើម្បីប្រតិបត្តិការប្រព័ន្ធនេះជាបន្ទាន់ ពីព្រោះថ្លៃចំណាយលើការឆ្លើយតបនឹងបញ្ហាប្រែប្រួលអាកាសធាតុនឹងកើនឡើងតាមអនុគមន៍អិចស្ប៉ូណង់ស្យែលប្រសិនបើពេលវេលាកន្លងទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០១៥

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព**

**សាយ សំអាល់**

# មាតិកា


១. សនិទានសម្រាប់សកម្មភាពការប្រែប្រួលអាកាសធាតុ៖ ផលប៉ះពាល់សេដ្ឋកិច្ច-សង្គម ពីការប្រែប្រួលអាកាសធាតុដែលបានប៉ាន់ស្មាននៅក្នុងប្រទេសកម្ពុជា ........ ១

ក) ផលប៉ះពាល់នៅថ្នាក់ជាតិ ........ ១

ខ) ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើការវិនិយោគជាក់លាក់ ........ ២

២. វិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា៖ កម្រិតបច្ចុប្បន្ននៃការចំណាយទាក់ទងនឹងអាកាសធាតុនិងវិធានការស្នើឡើងសម្រាប់ប្រាំឆ្នាំខាងមុខ ........ ៤

ក) ស្ថានភាពបច្ចុប្បន្ននៃការចំណាយលើគម្រោងអាកាសធាតុ ........ ៤

ខ) ស្ថានភាព និងថ្លៃចំណាយលើវិធានការដែលស្នើសម្រាប់រយៈពេលប្រាំឆ្នាំខាងមុខ ........ ៥

៣. ការណែនាំដើម្បីបង្កើតក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុដែលមានតម្លាភាព អាចទុកចិត្តបាន និងមានភាពទាក់ទាញ ........ ៩

ក) អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ........ ១១

ខ) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ........ ១២

គ) ក្រសួងផែនការ ........ 13

ឃ) ក្រសួង និងស្ថាប័នពាក់ព័ន្ធនៅក្នុងវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ........ ១៣

ង) ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការស្តារនិងអភិវឌ្ឍន៍កម្ពុជា (CDC/CRDB) ........ ១៤

ច) . លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងរដ្ឋបាលក្រោមជាតិ ........ ១៤

ឆ) ដៃគូអភិវឌ្ឍន៍ ........ 14


***សម្គាល់៖*** *យោងតាមកំណែទម្រង់បច្ចុប្បន្ន ក្របខ័ណ្ឌហិរញ្ញប្បទានអាកាសធាតុនេះទទួលការអនុម័តពីគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ(គ.ជ.គ.ប.អ.) កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤។ ដោយអនុលោមតាមព្រះរាជក្រឹត្យលេខនស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៥ រាល់បេសកកម្ម និងភារកិច្ចទាំងអស់របស់របស់ គ.ជ.គ.ប.អ.ត្រូវបានកែសម្រួល និងផ្ទេរភារកិច្ចឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព តាំងពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៥។*

## ១. សនិទានសម្រាប់សកម្មភាពការប្រែប្រួលអាកាសធាតុៈ ផលប៉ះពាល់សេដ្ឋកិច្ច-សង្គម ពីការប្រែប្រួលអាកាសធាតុដែលបានប៉ាន់ស្មាននៅក្នុងប្រទេសកម្ពុជា

### ក) ផលប៉ះពាល់នៅថ្នាក់ជាតិ

ការវិភាគដំបូងដោយផ្អែកលើសេណារីយ៉ូកំណើនសីតុណ្ហភាព ២អង្សាសេ នៅឆ្នាំ២០១៥ បានប៉ាន់ស្មានថា ការខូចខាតទាំងមូលបណ្តាលពីការប្រែប្រួលអាកាសធាតុមកលើចំណូលក្នុងស្រុកសរុប (GDP) របស់ប្រទេសកម្ពុជានឹងមានយ៉ាងហោចណាស់១,៥% នៅឆ្នាំ២០១៣០ និង៣,៥% នៅឆ្នាំ២០៥០។ ម៉្យាងវិញទៀតប្រសិនបើអត្រាកំណើនចំណូលក្នុងស្រុកសរុបប្រចាំឆ្នាំក្នុងករណីដែលគ្មានការប្រែប្រួលអាកាសធាតុកើតឡើងគេរំពឹងទុកថានឹងកើនឡើងរហូតដល់៤,៥% នៅឆ្នាំ២០៣០ តែអត្រានេះនឹងថយចុះមកត្រឹម ៣% វិញដោយសារតែផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ នៅឆ្នាំ២០៥០ អត្រាកំណើន GDP អាចស្ទើរតែបាត់បង់ទាំងស្រុង( ថយចុះមកត្រឹម ១% ប៉ុណ្ណោះ) ដែលបណ្តាលមកពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

ភាគច្រើននៃការខូចខាតទាំងនេះនឹងកើតឡើងបណ្តាលមកពីការកើនឡើងនៃការប្រែប្រួលរបបទឹកភ្លៀងដែលរួមបញ្ចូលទាំងហានិភ័យនានាដូចជា គ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតជាដើម។ ប្រភពចំបងនៃការខូចខាតនេះកើតចេញពីផលប៉ះពាល់នៃគ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់មកលើវិស័យកសិកម្ម( ១,៤២% នៃ GDP) កំណើនករណីជំងឺរាគរូសនិងជម្ងឺស្រួចស្រាវដទៃទៀតដែលទាក់ទងនឹងអាកាសធាតុ( ០,៨៥%នៃGDP) ការរេចរឹលនៃហេដ្ឋារចនាសម្ព័ន្ធកាន់តែឆាប់រហ័សដែលរួមមាន ផ្លូវថ្នល់ ប្រព័ន្ធស្រោចស្រព និងការផ្គត់ផ្គង់ទឹកនៅជនបទ( ០,៧១%) និងការខូចខាតដោយសារទឹកជំនន់មកលើហេដ្ឋារចនាសម្ព័ន្ធនៅទីក្រុង( ០,២៥% នៃ GDP)។

ការវិភាគនេះមានភាពស្របគ្នាជាមួយនិងការសិក្សានានាដែលមានស្រាប់នៅថ្នាក់តំបន់ និងអន្តរជាតិ។ ជាឧទាហរណ៍ ក្រុមការងារទី២សម្រាប់រៀបចំរបាយការណ៍វាយតម្លៃលើកទី៤របស់ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ( IPCC)បានពិនិត្យមើលអំពីការប៉ាន់ស្មានដ៏ទូលំទូលាយចំពោះការខូចខាតដែលអាចបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ដោយបានសន្និដ្ឋានថា កំណើនសីតុណ្ហភាព១-៣អង្សាសេ អាចកាត់បន្ថយ GDP អស់ពី១% ទៅ៥% ក្នុងនោះប្រទេសកំពុងអភិវឌ្ឍន៍រងការខូចខាតធ្ងន់ធ្ងរខ្លាំងជាងប្រទេសដទៃទៀត។

ផលប៉ះពាល់ទ្រង់ទ្រាយធំមកលើសេដ្ឋកិច្ច-សង្គមដែលបណ្តាលពីការប្រែប្រួលអាកាសធាតុអាចកាត់បន្ថយបាន តាមរយៈសកម្មភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ដែលមានប្រសិទ្ធភាព។ ការពិនិត្យថ្មីៗអំពីការចំណាយក្នុងវិស័យសាធារណៈដែលទាក់ទងនឹងអាកាសធាតុនៅក្នុងប្រទេសកម្ពុជាបានប៉ាន់ស្មានថា ការចំណាយ១,៣%នៃGDP បច្ចុប្បន្ននេះបានផ្តោតលើវិធានការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ សេណារីយ៉ូហិរញ្ញប្បទានអាកាសធាតុបានប៉ាន់ស្មានថាការចំណាយលើសកម្មភាពអាកាសធាតុ ដែលអាចមានខ្ពស់បំផុតគឺរហូតដល់១,៨%នៃGDP។ ក្រាហ្វិចខាងក្រោមបង្ហាញពីនិន្នាការនៃកំណើនGDP នៅក្នុងសេណារីយ៉ូខុសៗគ្នាចំនួនបួន។




*ក្រាហ្វិក១ ផលប៉ះពាល់រយៈពេលវែងនៃការប្រែប្រួលអាកាសធាតុ និងហិរញ្ញប្បទានអាកាសធាតុមកលើGDP*

| សេណារីយ៉ូនៃការឆ្លើយតប | ២០១៣* | ២០៣០* | ២០៥០* |
|---|---|---|---|
| សម្មតិកម្មនៃ GDP ប្រសិនបើគ្មានការប្រែប្រួលអាកាសធាតុ (CC) | ១៤,៩ | ៣៣,៨ | ៨១,៦ |
| GDPករណីមានការប្រែប្រួលអាកាសធាតុកើតឡើងតែគ្មានការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់នៅកម្រិតពិភពលោក(សេណារីយ៉ូ SRES A2) | ១៤,៩ | ២៩,១ | ៤២,១ |
| GDP ករណីមាន CC និងមានការកាត់បន្ថយកម្រិតពិភពលោក(SRES B1) តែគ្មានសកម្មភាពការបន្សាំ | ១៤,៩ | ២៩,៥ | ៤៥,១ |
| GDPករណីមានCC និងកាត់បន្ថយកម្រិតពិភពលោកនិងមានការបន្សាំតាមរយៈ១,៣% នៃGDP | ១៤,៩ | ៣១,៤ | ៥៦,១ |
| GDP ឧបមាថា CC និងកាត់បន្ថយកម្រិតពិភពលោកនិងការបន្សាំតាមរយៈ១,៨%នៃGDP | ១៤,៩ | ៣២,១ | ៦០,៧ |

* ពាន់លានដុល្លាអាមេរិក

### ខ) ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើការវិនិយោគជាក់លាក់

ការវិភាគថ្លៃចំណាយ-ផលចំណេញនៃការវិនិយោគនានាលើការប្រែប្រួលអាកាសធាតុបង្ហាញថា ការចំណាយទាំងនេះភាគច្រើនផ្តល់ផលចំណូលវិជ្ជមានខាងសេដ្ឋកិច្ច សូម្បីក្នុងករណីអវត្តមានការប្រែប្រួលអាកាសធាតុក៏ដោយ។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើផលចំណូលខាងសេដ្ឋកិច្ចមានការប្រែប្រួលដោយសកម្មភាពខ្លះៗ បង្កើតអត្ថប្រយោជន៍កម្រិតខ្ពស់(ជួនកាលត្រូវបានហៅថា“**សកម្មភាពមិនស្តាយក្រោយ**”)

និងសកម្មភាពខ្លះផ្តល់អត្ថប្រយោជន៍កម្រិតទាប (ជួនកាលហៅថាសកម្មភាព "**ប្រថុយនឹងអាកាសធាតុ**")។ ស្ថានភាពនេះត្រូវបានសង្ខេបតាមរយៈក្រាហ្វិកចំនួនពីរខាងក្រោម។

ជាឧទាហរណ៍ ការវិនិយោគលើប្រសិទ្ធភាពថាមពលច្រើនតែផ្តល់ផលចំណូលកម្រិតខ្ពស់ពីការវិនិយោគនានា បើទោះបីជាមិនគិតពីការប្រែប្រួលអាកាសធាតុ និងផ្តល់ផលកាន់តែខ្ពស់នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ។ ចំពោះការវិនិយោគលើថាមពលកកើតឡើងវិញ ស្ថានភាពនេះមានលក្ខណៈចម្រុះច្រើនដោយសារការវិនិយោគខ្លះ(ដូចជាថាមពលវារីអគ្គិសនី) ផ្តល់ផលចំណូលសេដ្ឋកិច្ចបានល្អនៅក្នុងលក្ខខណ្ឌដែលត្រឹមត្រូវ សូម្បីតែពុំបានគិតដល់ការសន្សំសំចៃនៃការបំភាយកាបូនក៏ដោយ ស្របពេលដែលការវិនិយោគផ្សេងៗទៀតអាចត្រូវការចំណាយខ្ពស់ជាងអគ្គិសនីដែលបានពីឥន្ធនៈផូស៊ីល។ ក្នុងវិស័យកសិកម្ម ការណែនាំឲ្យប្រើប្រាស់ពូជ និងការអនុវត្តនានាដែលធន់ទៅនឹងទឹកជំនន់និងគ្រោះរាំងស្ងួតផ្តល់ផលចំណូលបានល្អសូម្បីពុំគិតពីការប្រែប្រួលអាកាសធាតុក៏ដោយ ប៉ុន្តែផលចំណូលកាន់តែមានសារៈសំខាន់នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុដែលគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត នឹងកើតមានកាន់តែញឹកញាប់។




*ក្រាហ្វិក២ ផលធៀបរវាងអត្ថប្រយោជន៍និងថ្លៃចំណាយក្នុងករណីពុំគិត និងក្នុងករណីគិតពីការប្រែប្រួលអាកាសធាតុ-សកម្មភាពនានាដែលផ្តល់ផលចំណូលកាន់តែប្រសើរជាងមុន*

ហេដ្ឋារចនាសម្ព័ន្ធភាគច្រើន(ផ្លូវថ្នល់ ប្រព័ន្ធស្រោចស្រព សេវាអនាម័យ។ល។)នឹងផ្តល់ផលចំណូលកម្រិតទាបជាងនៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុដោយសារតែគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតនាំមកនូវតម្រូវការចំណាយខ្ពស់លើការថែទាំនិងការជួសជុល។ ទោះជាយ៉ាងណាក៏ដោយ ផលចំណូលសេដ្ឋកិច្ចកម្រិតខ្ពស់ជាងអាចទទួលបានតាមរយៈ ការកែលម្អការរៀបចំ ឬរចនាហេដ្ឋារចនាសម្ព័ន្ធ(ភាពធន់នឹងអាកាសធាតុ)ដែលបានយកចិត្តទុកដាក់អំពីគ្រោះទឹកជំនន់និងគ្រោះរាំងស្ងួតដែលនឹងកើតមានកាន់តែញឹកញាប់ជាងមុន (សូមមើលក្រាហ្វិចខាងក្រោម)។




*ក្រាហ្វិក ៣ ផលធៀបរវាងអត្ថប្រយោជន៍និងថ្លៃចំណាយសម្រាប់គម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដែលគិតគូរនិងដែលមិនគិតគូរអំពីការប្រែប្រួលអាកាសធាតុ*

## ២. វិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា៖ កម្រិតបច្ចុប្បន្ននៃការចំណាយទាក់ទងនឹងអាកាសធាតុ និងវិធានការស្នើឡើងសម្រាប់ប្រាំឆ្នាំខាងមុខ

### ក) ស្ថានភាពបច្ចុប្បន្ននៃការចំណាយលើគម្រោងអាកាសធាតុ

ការវិភាគលើការចំណាយសាធារណៈដែលពាក់ព័ន្ធនឹងអាកាសធាតុត្រូវបានធ្វើឡើងសម្រាប់ចន្លោះឆ្នាំ ២០០៩-២០១២ ដែលរួមទាំងការចំណាយថវិកាជាតិ និងការចំណាយមូលនិធិពីម្ចាស់ជំនួយនានាក្រៅក្របខ័ណ្ឌថវិកាជាតិ។ ការចំណាយដែលទាក់ទងនឹងអាកាសធាតុត្រូវបានកំណត់ដោយប្រើប្រាស់វិធីសាស្ត្រដែលផ្អែកលើអត្ថប្រយោជន៍៖ ប្រសិនបើ៥០%នៃអត្ថប្រយោជន៍ពីការវិនិយោគណាមួយកើតឡើងដោយសារតែការប្រែប្រួលអាកាសធាតុ ការវិនិយោគនោះត្រូវបានចាត់ទុកថាមាន៥០%ពាក់ព័ន្ធនឹងអាកាសធាតុ។ ការវិនិយោគខ្លះដូចជាទំនប់ការពារកំណើនកំពស់ទឹកសមុទ្រគឺពាក់ព័ន្ធ១០០%នឹងការប្រែប្រួលអាកាសធាតុ។ ការវិនិយោគដទៃទៀត ដូចជាលើប្រសិទ្ធភាពថាមពល ឬ ថាមពលកកើតឡើងវិញមានអត្ថប្រយោជន៍ដែលភាគច្រើនជាអត្ថប្រយោជន៍ខាងសេដ្ឋកិច្ចត្រឹមតែ២៧% នៃអត្ថប្រយោជន៍ទាំងនេះប៉ុណ្ណោះ ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ(បណ្តាលពីការថយចុះនៃការបំភាយឧស្ម័នផ្ទះកញ្ចក់)។ ផ្អែកលើវិធីសាស្ត្រនេះ កម្រិតចំណាយដែលទាក់ទងនឹងអាកាសធាតុបានកើនឡើងជាបន្តបន្ទាប់ពី០,៨៦%នៃ GDP (៣៦៨ពាន់លានរៀល) នៅឆ្នាំ ២០០៩ ដល់១,២៩% នៃ GDP (៧៤១ពាន់លានរៀល)នៅឆ្នាំ២០១២។ ស្ថានភាពដែលត្រូវគ្នានេះនឹងការចំណាយដែលពាក់ព័ន្ធនឹងអាកាសធាតុមានដូចខាងក្រោម៖




*ក្រាហ្វិក៤ ការចំណាយលើការប្រែប្រួលអាកាសធាតុ ឆ្នាំ២០០៩-២០១២ (ពាន់លានរៀល)*

តួនាទីរបស់វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល(NGOs) នៅក្នុងហិរញ្ញវត្ថុអាកាសធាតុនឹងកាន់តែសំខាន់ នៅពេលដែលប្រទេសកម្ពុជាអភិវឌ្ឍន៍ដោយសារតែការវិនិយោគតម្រូវឲ្យមានការកាត់បន្ថយការបំភាយឧស្ម័ន និងតម្រូវឲ្យមានការលើកកំពស់ការយល់ដឹងជាសាធារណៈ ព្រមទាំងការបញ្ចុះបញ្ចូលក្រុមហ៊ុនទទួលខុសត្រូវលើផ្នែកសង្គម។ សក្តានុពលពេញលេញសម្រាប់ហិរញ្ញប្បទានតាមរយៈទីផ្សារកាបូនដែលកំពុងតែស្ថិតនៅក្នុងស្ថានភាពមិនប្រាកដប្រជា ដោយសារតែអវត្តមានកិច្ចព្រមព្រៀងអន្តរជាតិដែលរំពឹងថានឹងសម្រេចបាននៅឆ្នាំ២០១៥។ វិស័យឯកជនមានឱកាសគ្រប់គ្រាន់ដើម្បីធ្វើការវិនិយោគលើប្រសិទ្ធភាពថាមពលដោយសារតែផលចំណូលខាងសេដ្ឋកិច្ចមានអត្រាខ្ពស់បន្ថែមលើអត្ថប្រយោជន៍ក្នុងការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់។ ការវិនិយោគនេះទាមទារឲ្យមានហិរញ្ញប្បទានដើម្បីបំពេញថ្លៃចំណាយដំបូងលើការវិនិយោគ។ ការសាកល្បងក្នុងពេលថ្មីៗ នេះក្នុងឧស្សាហកម្មកម្មន្តសាលបានបង្ហាញពីផលចំណូលជាមធ្យមពីការិនិយោគកម្រិត៨២%ក្នុងរយៈពេលនៃឆ្នាំដំបូង ដែលផ្តល់នូវការលើកទឹកចិត្តកម្រិតខ្ពស់សម្រាប់ពង្រីកការវិនិយោគពីផ្នែកឯកជនក្នុងវិស័យនេះ។

### ខ) ស្ថានភាព និងថ្លៃចំណាយលើវិធានការដែលស្នើសម្រាប់រយៈពេលប្រាំឆ្នាំខាងមុខ

វិធានការនៅថ្នាក់ជាតិឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុអាចមានគោលដៅដោះស្រាយត្រឹមតែមួយផ្នែកនៃការខូចខាតសរុបដែលបង្កដោយការប្រែប្រួលអាកាសធាតុប៉ុណ្ណោះ ដោយសារតែការបញ្ចៀសនូវការខូចខាតខ្លះៗ ដែលជាក់ស្តែងមិនអាចធ្វើបាន ឬការចំណាយដែលពុំមានប្រសិទ្ធភាព។ សមាមាត្រខ្ពស់បំផុត

់នៃការខូចខាតដែលអាចជៀសវាងបានគឺអាស្រ័យលើស្ថានភាពជាក់លាក់នៅក្នុងប្រទេសនីមួយៗ។ យោងតាមរបាយការណ៍ស្នើន ប្រទេសនានាអាចមានគោលដៅដោះស្រាយប្រមាណពីរភាគបីនៃការខូចខាតនេះ។ នៅប្រទេសកម្ពុជា ការធ្វើបែបនេះទាមទារនូវការចំណាយលើការបន្សាំរហូតដល់ ៣,៣%នៃGDP (ធៀបនឹង ១,២២% នៅឆ្នាំ២០១២) រវាងបច្ចុប្បន្ន និងឆ្នាំ២០៥០។

ទោះជាយ៉ាងណាក៏ដោយ គេត្រូវគិតបញ្ចូលឧបសគ្គខាងហិរញ្ញវត្ថុនិងសមត្ថភាពមុននឹងអាចទទួលបានមូលនិធិកម្រិត *‘ខ្ពស់’* សម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ការវិភាគសេណារីយ៉ូដែលអាចមានទាក់ទងនឹងការផ្តល់មូលនិធិត្រូវបានធ្វើឡើងសម្រាប់អំឡុងឆ្នាំ ២០១៤-២០១៨ ដោយផ្តោតលើធនធានក្នុងវិស័យសាធារណៈដែលពាក់ព័ន្ធនឹងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា៖

(ក) **<u>មូលនិធិផ្តោតលើអាកាសធាតុ/ពិភពលោក</u>** គឺជាហិរញ្ញវត្ថុដែលបានពីស្ថាប័ន និងយន្តការពិភពលោកសម្រាប់ការប្រែប្រួលអាកាសធាតុ ជាឧទាហរណ៍ៈ មូលនិធិវិនិយោគអាកាសធាតុ(CIF) ដែលរួមទាំង SPCR, GEF, LDCF, AF, FCPF[1], UN-REDD[2] និងមូលនិធិអាកាសធាតុបៃតងដែលនឹងមានក្នុងពេលឆាប់ៗ ខាងមុខនេះដែលផ្តោតលើការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុតាមរយៈវិធានការកាត់បន្ថយឬវិធានការបន្សាំ។

(ខ) **<u>មូលនិធិផ្តោតលើអាកាសធាតុ/ក្នុងប្រទេស</u>** គឺជាចំណែកនៃមូលនិធិអាកាសធាតុដែលផ្តោតជាក់ស្តែងលើការដោះស្រាយបញ្ហាអាកាសធាតុដែលទទួលបានដោយផ្ទាល់ពីរដ្ឋាភិបាលកម្ពុជា តាមរយៈថវិកាប្រចាំឆ្នាំរបស់ខ្លួន ឬ តាមរយៈម្ចាស់ជំនួយទ្វេភាគី និងពហុភាគីដែលប្រតិបត្តិការនៅកម្ពុជា។

(គ) **<u>មូលនិធិចម្រុះ/ក្នុងប្រទេស</u>** សំដៅលើប្រភេទធនធានដែលបានទទួលពីរដ្ឋាភិបាល និងម្ចាស់ជំនួយនៅកម្ពុជាដែលមិនមែនផ្តោតជាបឋមលើបញ្ហាអាកាសធាតុឡើយ ប៉ុន្តែមានការពាក់ព័ន្ធខ្លះៗ(កម្រិតទាបនិងមធ្យម)ទៅនឹងការប្រែប្រួលអាកាសធាតុផ្ទាល់ ឬដោយប្រយោល។ នៅក្នុងហិរញ្ញវត្ថុប្រភេទនេះ បញ្ហាអាកាសធាតុត្រូវបានដាក់បញ្ចូល ឬ បង្កប់នៅក្នុងគម្រោងអភិវឌ្ឍន៍នានា។

ធនធានសាធារណៈទាំងនេះដែលកម្ពុជាអាចប្រើប្រាស់សម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុមានទំហំធំជាងហិរញ្ញវត្ថុអាកាសធាតុ **“ថ្មីនិងបន្ថែម”** ដែលបានកត់សម្គាល់នៅក្នុងការប្តេជ្ញាក្រោមអនុសញ្ញា UNFCCC(ការប្តេជ្ញាទាំងនេះមានក្នុងចំណុច(ក)និងមួយចំណែកពីម្ចាស់ជំនួយនៅក្នុង(ខ)ប៉ុណ្ណោះ)។ គេចាំបាច់ត្រូវតាមដានទាំងហិរញ្ញវត្ថុអាកាសធាតុ**“ថ្មីនិងបន្ថែម”** ដើម្បីធានាថាធនធានទាំងអស់ដែលអាចទ្រទ្រង់វិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុត្រូវបានប្រមូលផ្តុំសម្រាប់ប្រើប្រាស់។

សេណារីយ៉ូដំបូងបង្ហាញថា ចំនួនសរុបនៃហិរញ្ញវត្ថុអាកាសធាតុក្នុងវិស័យសាធារណៈអាចកើនពីប្រមាណ ១៨៥លានដុល្លាអាមេរិកនៅឆ្នាំ២០១៣ ដល់២៥៥លានដុល្លាអាមេរិក(កើនឡើងតិចតួច) ឬ ៣០០លានដុល្លាអាមេរិក(កើនឡើងខ្លាំង) ក្នុងមួយឆ្នាំៗរហូតដល់ឆ្នាំ២០១៨។ ការបែងចែកធនធានក្នុងមូលនិធិអាកាស

[1] មូលនិធិភាពជាដៃគូកាបូនព្រៃឈើ

[2] កម្មវិធីសហការនៃអ.ស.ប ស្តីពីការកាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ។

ជាតុពិភពលោកត្រូវបានរំពឹងថានឹងកើនឡើងឆាប់រហ័ស ប៉ុន្តែធនធានមួយចំណែកធំនៅក្នុងអំឡុងពេលនេះ នឹងត្រូវផ្តល់ដោយរដ្ឋាភិបាល និងម្ចាស់ជំនួយនានានៅក្នុងប្រទេសតាមរយៈហិរញ្ញវត្ថុដែលផ្តោតលើអាកាស ជាតុ ឬ ជាផ្នែកមួយនៃគម្រោងអភិវឌ្ឍន៍ទូទៅ។




*ក្រាហ្វិក៥ ការវិវត្តដែលចង្អុលបង្ហាញពីហិរញ្ញវត្ថុអាកាសធាតុ(២០១៤-២០១៨) សេណារីយ៉ូកំណើនកម្រិតទាប*

បន្ថែមលើឧបសគ្គខាងហិរញ្ញប្បទាន សមត្ថភាពដែលមានស្រាប់ក្នុងការអនុវត្តកម្មវិធីប្រែប្រួលអាកាស ជាតុក៏ត្រូវតែជាចំណែកមួយដែលត្រូវពិចារណាផងដែរ នៅពេលកសាងផែនការសម្រាប់វិធានការឆ្លើយតប ដែលបានស្នើឡើង។ ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា និងផែនការសកម្មភាពប្រែប្រួល អាកាសធាតុនៃក្រសួងអាទិភាពបានកំណត់អត្តសញ្ញាណការត្រៀមរៀបចំសំខាន់ៗ មួយចំនួនសម្រាប់អនុវត្ត ន៍វិធានការឆ្លើយតបដែលបានស្នើឡើងឲ្យបានពេញលេញ។ ការអភិវឌ្ឍសមត្ថភាព និងគោលនយោបាយការ កសាងផែនការ និងការសិក្សាស្រាវជ្រាវ តំណាងឲ្យប្រមាណ២៥% នៃវិធានការឆ្លើយតបដែលបានស្នើឡើង នៅក្នុងក្រសួងអាទិភាពទាំងប្រាំបួនសម្រាប់រយៈពេលប្រាំឆ្នាំខាងមុខ ហើយភាគរយនេះត្រូវបានរំពឹងថានឹង ថយចុះនៅពេលដែលកម្ពុជាមានសមត្ថភាពសម្រាប់កសាងផែនការ និងគ្រប់គ្រងវិធានការរបស់ខ្លួនឆ្លើយតប នឹងការប្រែប្រួលអាកាសធាតុ។




*ក្រាហ្វិក៦ ការចំណាយដែលគ្រោងសម្រាប់២០១៤-២០១៨ ក្នុងផែនការសកម្មភាពប្រែប្រួលអាកាសធាតុនៃក្រសួងអាទិភាពទាំងប្រាំបួន (គិតជាដុល្លារអាមេរិក)*

ផ្អែកតាមផែនការសកម្មភាពដែលមានស្រាប់ និងការប៉ាន់ស្មានសម្រាប់វិស័យនានាដែលពុំទាន់មានផែនការសកម្មភាពនៅឡើយការឆ្លើយតបសរុបក្នុងវិស័យសាធារណៈត្រូវបានប៉ាន់ស្មានថាមានតម្លៃ ១,១ពាន់លានដុល្លារអាមេរិក សម្រាប់អំឡុងឆ្នាំ២០១៤-២០១៨ ដូចតទៅ៖




*ក្រាហ្វិក៧ តួលេខប៉ាន់ស្មានការវិភាជន៍ពីប្រភពសាធារណៈសម្រាប់ចំណាយក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ឆ្នាំ២០១៤-២០១៨*

*ប្រភព៖ សេចក្តីព្រាង CCAPs (ខែមីនា ឆ្នាំ២០១៤) និងសេណារីយ៉ូហិរញ្ញប្បទាន CCFF*

សក្តានុពលនៃការគាំទ្រហិរញ្ញវត្ថុពីវិស័យឯកជនដល់វិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅតែមិនប្រាកដប្រជា។ វិស័យឯកជនមានសក្តានុពលក្នុងការវិនិយោគលើប្រសិទ្ធភាពថាមពលដូចមានសាកល្បងថ្មីៗនេះក្នុងឧស្សាហកម្មកម្មន្តសាល និងកសិ-ឧស្សាហកម្ម ដែលបានបង្ហាញពីផលចំណូលឆាប់រហ័សយ៉ាងខ្លាំងពីការវិនិយោគក្នុងវិស័យនេះ។ ទាក់ទងនឹងទីផ្សារកាបូនសក្តានុពលខាងហិរញ្ញប្បទានពុំមានភាពប្រាកដប្រជាឡើយដោយសារគ្មានការឯកភាពជាអន្តរជាតិដែលឈានដល់កិច្ចព្រមព្រៀងជាប់ជាកាតព្វកិច្ចផ្លូវច្បាប់នៅឡើយ ហើយប្រទេសនីមួយៗទំនងជាងាកចេញពីយន្តការដែលមានបច្ចុប្បន្នដូចជាយន្តការអភិវឌ្ឍន៍ស្អាត និងព្យាយាមបង្កើតគំរូរបស់ខ្លួនផ្ទាល់សម្រាប់ទីផ្សារកាបូន។ ថ្លៃកាបូនមានភាពប្រែប្រួលជាខ្លាំងហើយបច្ចុប្បន្ននេះនៅមានកម្រិតទាប។ ក្នុងករណីគម្រោងយន្តការអភិវឌ្ឍន៍ស្អាត ឥឡូវនេះថ្លៃកាបូនមានត្រឹម១-២ដុល្លាអាមេរិកក្នុង១តោនសមមូល$CO_2$(ពោលគឺថយចុះពីប្រមាណ២០ដុល្លាអាមេរិចនៅឆ្នាំ១៩៩៧ និង ៥-៨ ដុល្លាអាមេរិចនៅឆ្នាំ២០១១) និងប្រមាណ៤-៨ដុល្លាអាមេរិចក្នុង១តោនសមមូល$CO_2$ សម្រាប់ឥណទានគម្រោង REDD។

## ៣.ការណែនាំដើម្បីបង្កើតក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុដែលមានតម្លាភាព អាចទុកចិត្តបាន និងមានភាពទាក់ទាញ

កម្ពុជាបានចាត់វិធានការធំៗខ្លះរួចមកហើយ ក្នុងការបង្កើតយន្តការដ៏រឹងមាំដើម្បីគ្រប់គ្រងហិរញ្ញវត្ថុអាកាសធាតុ។ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុនិងអគ្គលេខាធិការដ្ឋានត្រូវបានបង្កើតឡើងដោយមានអាណត្តិសម្របសម្រួលវិធានការជាតិឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ផែនការយុទ្ធសាស្ត្រមួយរយៈពេលដប់ឆ្នាំ ពោលគឺផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជាឆ្នាំ២០១៤-២០២៣ ក៏ត្រូវបានដាក់ឲ្យអនុវត្តន៍ហើយក្រសួងជាអាទិភាពចំនួនប្រាំបួនបានបង្កើតផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពតាមវិស័យរបស់ខ្លួនរួចហើយដែរ។ នៅថ្នាក់ក្រោមជាតិមានការចាប់ផ្តើមបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងការកសាងផែនការ និងការលើកថវិកានៅថ្នាក់ខេត្ត ស្រុក និងឃុំនានា ដោយផ្អែកតាមមេរៀនដែលទទួលបានពីគម្រោងសាកល្បងមួយចំនួន។

ទោះជាយ៉ាងណាក៏ដោយ នៅមានការងារជាច្រើនដែលសម្រេចឲ្យបានដើម្បីកែលម្អការសម្របសម្រួលរវាងរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍លើការងារប្រែប្រួលអាកាសធាតុដើម្បីអាចតាមដានបានប្រសើរជាងមុននូវការចំណាយលើអាកាសធាតុ និងប៉ាន់ប្រមាណពីប្រសិទ្ធផលនិងឥទ្ធិពលនៃការចំណាយទាំងនោះដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុឲ្យបានពេញលេញនៅក្នុងការគ្រប់គ្រងសាធារណៈ(គោលនយោបាយ ការកសាងផែនការ ការលើកថវិកា ការអនុវត្ត ការតាមដាន និងការវាយតម្លៃ) និងនិយ័តកម្ម ព្រមទាំងដើម្បីបង្កើតការលើកទឹកចិត្តដើម្បីឲ្យវិស័យឯកជនចូលរួមចំណែក។

ដើម្បីគ្រប់គ្រងអន្តរកាលនេះមានការស្នើថាកម្ពុជាគួរបង្កើតមូលនិធិជាតិអាកាសធាតុ(NCFF)ដែលមានលក្ខណៈសំខាន់ៗ ដូចតទៅ៖

| | |
|---|---|
| ១ | មូលនិធិNCFFនឹងគ្របដណ្តប់រាល់គោលនយោបាយកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់និងបន្សាំនឹងការប្រែប្រួលអាកាសធាតុដែលរួមទាំងរដ្ឋាភិបាល និងម្ចាស់ជំនួយ ការវិនិយោគ ការចំណាយចរន្ត និង និយ័តកម្មព្រមទាំងការលើកទឹកចិត្តក៏ដូចជាការចំណាយផងដែរ។ |
| ២ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព( NCSD)នឹងផ្តល់ការដឹកនាំហើយលេខាធិការដ្ឋាននៃក្រុមប្រឹក្សានេះនឹងផ្តល់ការគាំទ្របច្ចេកទេស។ ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា( CCCSP) ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុតាមវិស័យ (CCSPs) និងផែនការសកម្មភាពប្រែប្រួលអាកាសធាតុ (CCAPs) នឹងត្រូវធ្វើបច្ចុប្បន្នភាពដើម្បីផ្តល់ការណែនាំជាយុទ្ធសាស្ត្រ។ |
| ៣ | និយមន័យហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុនឹងត្រូវកំណត់ដោយផ្អែកលើថាតើអត្ថប្រយោជន៍ពីគោលនយោបាយ/សកម្មភាពណាមួយនឹងរងឥទ្ធិពលពីការប្រែប្រួលអាកាសធាតុឬទេដោយប្រើប្រាស់សំណៅវិធីសាស្ត្រដែលមានអធិប្បាយនៅក្នុងឯកសារនេះ និងដែលបានអនុម័តគាំទ្រតាមរយៈបញ្ញត្តិច្បាប់។ |
| ៤ | កម្រិតនៃការផ្តល់មូលនិធិប្រែប្រួលអាកាសធាតុនឹងត្រូវដាក់បញ្ចូលជាបណ្តើរៗនៅក្នុងថវិកាជាតិ និង ក្នុងគណនីរបស់រដ្ឋាភិបាលដោយប្រើប្រាស់សញ្ញាសំគាល់ និងពិន្ទុនៅក្នុងប្រព័ន្ធ PFM។ |
| ៥ | NCSD នឹងមាននាទីជាស្ថាប័នអនុវត្តរបស់ជាតិ(NIE) សម្រាប់AF និង GCF ហើយការផ្តល់មូលនិធិតាមរយៈNIEនឹងវិវត្តទៅជាផ្នែកមួយនៃថវិកានិងបានពីរតនាគារជាតិ ទោះបីពីដំបូងគេអាចប្រើប្រាស់ត្រឹមគណនីគម្រោង និងគណនីពិសេសនៅក្នុងរតនាគារក៏ដោយ។ |
| ៦ | ម្ចាស់ជំនួយនឹងបានទទួលការលើកទឹកចិត្តដើម្បីរួមបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងគម្រោងទាំងអស់ដែលមានការពាក់ព័ន្ធតាមរយៈការជ្រើសរើសគម្រោងរបស់ម្ចាស់ជំនួយនៅក្នុងដំណាក់កាលកំណត់យុទ្ធសាស្ត្ររបស់ប្រទេស និងការកំណត់រកគម្រោង។ ចំណុចនេះនឹងត្រូវអនុវត្តសម្រាប់គ្រប់គំរូទាំងអស់ដែលរួមទាំងការគាំទ្រវិស័យណាមួយឬការគាំទ្រថវិកាជាទូទៅ។ ម្ចាស់ជំនួយនឹងបានទទួលការលើកទឹកចិត្តឲ្យប្រមូលផ្តុំធនធានរួមគ្នានៅក្នុងករណីដែលអាចធ្វើបាន។ |
| ៧ | ការគាំទ្រនៃវិស័យសាធារណៈដល់ការកាត់បន្ថយការបញ្ចេញឧស្ម័ននឹងងាកចេញជាបណ្តើរៗពីជំនួយឥតសំណង និងការវិនិយោគផ្ទាល់ទៅរកគំរូនានាដែលលើកទឹកចិត្តដល់វិស័យឯកជនដើម្បីវិនិយោគលើការកាត់បន្ថយ។ |
| ៨ | អាជ្ញាធរនៅថ្នាក់ក្រោមជាតិនឹងទទួលបានចំណែកកាន់តែច្រើននៃហិរញ្ញវត្ថុអាកាសធាតុ ក្នុងករណីដែលដំណើរការ PFM នៅតែមានជោគជ័យ។ ការធ្វើបែបនេះបានអាចទាមទារឲ្យមានវិមជ្ឍការសកម្មភាពខ្លះៗបន្ថែមទៀត។ |
| ៩ | លេខាធិការដ្ឋាន NCSD នឹងរក្សាក្របខ័ណ្ឌអ្នកជំនាញការកម្ពុជាដែលធ្វើការនៅក្នុងផ្នែកកសាងផែនការនៃក្រសួងពាក់ព័ន្ធដើម្បីជួយរួមបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំគម្រោង និង ឯកសារថវិកា។ តាមធម្មតាកិច្ចការនេះនឹងធ្វើឡើងជាទម្រង់នៃការគាំទ្រក្នុងការងារផ្ទាល់ដែលផ្សារ |

| | |
|---|---|
| | ភ្ជាប់ទៅនឹងការសម្រេចលើចំណាយសម្រាប់កិច្ចការប្រែប្រួលអាកាសធាតុ។ |
| ១០ | NCCC នឹងរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពីហិរញ្ញវត្ថុអាកាសធាតុ(APR) ដែលនឹងកត់ត្រានិន្នាការក្នុងការចំណាយ និងភស្តុតាងនានាដែលមានស្តីពីប្រសិទ្ធភាពនៃការចំណាយ។ |
| ១១ | NCFF ធ្វើការឆ្ពោះទៅរកទីបញ្ចប់រហូតដល់ឆ្នាំ២០២៣ ដែលនៅដំណាក់កាលនោះ មួយភាគធំនៃហិរញ្ញវត្ថុអាកាសធាតុត្រូវបានផ្តល់តាមរយៈការគាំទ្រថវិកាដែលរួមទាំងការគាំទ្រថវិកាតាមវិស័យ និងការគាំទ្រថវិកាទូទៅ។ |

NCFF សម្របសម្រួលសម្រាប់ការចាត់ចែងផ្តល់មូលនិធិតាមរបៀបខុសៗ គ្នាដែលរួមទាំងរាល់រចនាសម្ព័ន្ធចាត់ចែងដែលកំពុងប្រើប្រាស់បច្ចុប្បន្ននេះផងដែរ។ NCFF នឹងបង្កើនវឌ្ឍនភាពទៅរកការចូលរួមនិងការទទួលខុសត្រូវកាន់តែច្រើនឡើងរបស់រដ្ឋាភិបាល ប៉ុន្តែមិនបង្ខំឲ្យរដ្ឋាភិបាល ឬម្ចាស់ជំនួយចូលរួមនៅក្នុងប្រព័ន្ធគ្រប់គ្រងរួមមួយ ដូចជាមូលនិធិជាតិអាកាសធាតុឡើយ។ ការវិភាគអំពីសេណារីយ៉ូហិរញ្ញប្បទានអាកាសធាតុនិងទស្សនវិស័យរបស់ម្ចាស់ជំនួយស្តីពីគំរូនៃការផ្តល់ជំនួយនៅកម្ពុជាបង្ហាញថាមូលនិធិបែបនេះមិនទំនងជាបង្កើនធនធានច្រើនឡើយនៅក្នុងរយៈពេលខ្លីទៅមធ្យម។ ការពិនិត្យឱកាសដើម្បីបង្កើតស្ថាប័នមូលនិធិមួយត្រូវបានស្នើឡើងជាផ្នែកមួយនៃការពិនិត្យCCCSP ពាក់កណ្តាលអាណត្តិនៅក្នុងឆ្នាំ២០១៨ នៅពេលដែលមានការអះអាងបន្ថែមអំពីគំរូនានាសម្រាប់ហិរញ្ញប្បទានអាកាសធាតុអន្តរជាតិ និងបន្ទាប់ពីបានបញ្ចប់ដំណាក់កាលបច្ចុប្បន្ននៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា។

គ្រឹះស្ថាននានាដូចខាងក្រោមនេះនឹងមានការទទួលខុសត្រូវអនុវត្តន៍មូលនិធិជាតិអាកាសធាតុដូចតទៅ៖

### ក) អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

- បង្កើតយន្តការសម្របសម្រួលរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍សម្រាប់ការអនុវត្តCCCSP និងផែនការសកម្មភាពដែលត្រូវគ្នានេះ។ យន្តការនេះនឹងធានាយ៉ាងហោចណាស់រាល់អន្តរាគមន៍ដែលទាក់ទងនឹងអាកាសធាតុត្រូវបានលើកផែនការនិងថវិកាស្របជាមួយCCCSP/CCAPs និងរួមចំណែកនៅក្នុងក្របខ័ណ្ឌជាតិសម្រាប់តាមដាន និងវាយតម្លៃអំពីការប្រែប្រួលអាកាសធាតុ។
- កែតម្រូវលក្ខខណ្ឌនៃច្បាប់ (ដូចជា អង្គភាពស្វយ័តអន្តរក្រសួង) និងនីតិវិធីធ្វើការតាមការចាំបាច់ និងដាក់ពាក្យសុំទៅមូលនិធិបន្សាំ និងមូលនិធិអាកាសធាតុបៃតង ឲ្យទទួលស្គាល់ស្ថាប័នអនុវត្តន៍របស់ជាតិ។
- ក្រោមភាពជាដៃគូជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង CDC-CRDB ត្រូវបង្កើតនីតិវិធីសម្រាប់ការតាមដានប្រចាំឆ្នាំលើការចំណាយក្នុងវិស័យសាធារណៈដែលពាក់ព័ន្ធនឹងអាកាសធាតុ។ កិច្ចការនេះនឹងត្រូវវិវត្តជាបន្តបន្ទាប់ពីការពិនិត្យប្រចាំឆ្នាំជាករណីពិសេស ដើម្បីរួមបញ្ចូលវិធីតាមដានការប្រែប្រួលអាកាសធាតុនៅក្នុងកម្រងទិន្នន័យថវិកាជាតិ និងកម្រងទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA)។

- ក្រោមភាពជាដៃគូជាមួយក្រសួងផែនការ និងក្រសួងពាក់ព័ន្ធនានា ត្រូវបង្កើតក្របខ័ណ្ឌតាមដាន និងវាយតម្លៃដែលកំពុងដំណើរការសម្រាប់ការប្រែប្រួលអាកាសធាតុ និងរៀបចំការវិភាគជាទៀងទាត់អំពីផលប៉ះពាល់នៃវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដែលរួមទាំងការពិនិត្យជាទៀងទាត់លើការអនុវត្ត CCCSP
- ក្រោមកិច្ចសហការជាមួយសកលវិទ្យាល័យ និងគ្រឹះស្ថានបណ្តុះបណ្តាលដែលពាក់ព័ន្ធ ត្រូវរៀបចំនិងគ្រប់គ្រងកម្មវិធីអភិវឌ្ឍន៍ជំនាញ ដែលឆ្លើយតបនឹងតម្រូវការរបស់ក្រុមសំខាន់ៗនៃមន្ត្រីរដ្ឋាភិបាលដែលពាក់ព័ន្ធនៅក្នុងវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (ការវិភាគគោលនយោបាយការកសាងផែនការនិងថវិកា ការតាមដាននិងការពិនិត្យលើការចំណាយ ការវាយតម្លៃផលប៉ះពាល់ ។ល។)
- ផ្តល់ការគាំទ្របច្ចេកទេសដល់សមាជិក NCSD ដើម្បីទទួលបានហិរញ្ញវត្ថុអាកាសធាតុនិងការគ្រប់គ្រងដែលរួមទាំង ការបង្កើតគម្រោង និងលើកថវិកា និងការតាមដានលទ្ធផលនៃការប្រែប្រួលអាកាសធាតុ
- ផ្តល់យោបល់ដល់ NCSD និងសមាជិកគណៈកម្មាធិការនេះ អំពីការកែប្រែសមស្របខាងផ្នែកច្បាប់និងបទប្បញ្ញត្តិនានាសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុ ទៅក្នុងការកសាងផែនការ និងការអនុវត្ត និងក្នុងការគោរពតាមកាតព្វកិច្ចជាអន្តរជាតិរបស់កម្ពុជា
- បង្កើតយន្តការសន្ទនាជាមួយវិស័យឯកជន អំពីវិធានការដែលមានសក្តានុពលដើម្បីសម្រួលដល់ការវិនិយោគរបស់វិស័យឯកជនលើវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
- ក្រោមភាពជាដៃគូជាមួយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាក់ព័ន្ធត្រូវធ្វើការវិភាគស៊ីជម្រៅអំពីសេដ្ឋកិច្ចនៃការប្រែប្រួលអាកាសធាតុដែលនាំមកនូវអនុសាសន៍គោលនយោបាយស្តីពីវិធានការបន្សាំ និងការកាត់បន្ថយដែលកាន់តែមានប្រសិទ្ធភាពនៅក្នុងបរិបទកម្ពុជា និងធ្វើការប៉ាន់ស្មានឲ្យសុក្រឹត្យជាងមុនអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើលក្ខខណ្ឌសេដ្ឋកិច្ច និងសង្គមកម្ពុជា។

## ខ) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- កែលម្អការវិភាគថ្លៃចំណាយ-ផលចំណេញអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើសេដ្ឋកិច្ច(ក្រោមកិច្ចសហការជាមួយ SNEC និង NCCC) និងអំពីការចំណាយ/ការវិនិយោគ/គោលនយោបាយនានា និងបម្លែងរបកគំហើញនានាឲ្យទៅជាអនុសាសន៍សម្រាប់រួមបញ្ចូលទៅក្នុងឯកសារថវិកាជាតិ (ដូចជា ផែនការយុទ្ធសាស្រ្តថវិកា) និងដំណើការនានា
- ក្រោមភាពជាដៃគូជាមួយ NCSD ត្រូវធ្វើការវិភាគប្រចាំឆ្នាំអំពីការចំណាយក្នុងវិស័យសាធារណៈដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុដើម្បីតាមដានស្ថានភាពនៃវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ ក្នុងរយៈពេលមធ្យមត្រូវរួមបញ្ចូលវិធានការតាមដានការចំណាយលើអាកាសធាតុនៅក្នុងថវិកាជាតិ ដែលនៅពេលមានកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលនាំទៅរកការអនុវត្តថវិកាកម្មវិធីបានពេញលេញ

- រួមជាមួយ NCSD ត្រូវដឹកនាំការសន្ទនាជាមួយម្ចាស់ជំនួយហិរញ្ញវត្ថុអាកាសធាតុ អំពីគំរូនានាសម្រាប់ការរួមបញ្ចូលជាបណ្តើរៗនូវហិរញ្ញវត្ថុអាកាសធាតុទៅក្នុងប្រព័ន្ធថវិកាជាតិ
- រួមបញ្ចូលបញ្ហា/គំរូនៃហិរញ្ញវត្ថុអាកាសធាតុទៅក្នុងកញ្ចប់ស្តង់ដារសម្រាប់ការបណ្តុះបណ្តាលមន្ត្រីរដ្ឋាភិបាលស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ចូលរួមនៅក្នុងការសន្ទនាមួយជាមួយវិស័យឯកជនអំពីគោលនយោបាយដែលមានសក្តានុពលសម្រាប់លើកកំពស់ការវិនិយោគពីវិស័យឯកជននៅក្នុងវិធានការឆ្លើយតបនឹងអាកាសធាតុ ជាពិសេសការកាត់បន្ថយ។

### គ) ក្រសួងផែនការ

- ក្រោមភាពជាដៃគូជាមួយ NCSD ត្រូវប្រមូលនិងវិភាគទិន្នន័យអំពីសូចនាករដែលទាក់ទងនឹងអាកាសធាតុនៅក្នុង NSDPដោយផ្ទាល់( តាមរយៈ NIS)ឬតាមរយៈគោលការណ៍ណែនាំនិងការគាំទ្រគ្រប់គ្រាន់ដល់ក្រសួងពាក់ព័ន្ធ
- ក្រោមភាពជាដៃគូជាមួយ NCSD និង NCDD ត្រូវរួមបញ្ចូលការប្រែប្រួលអាកាសធាតុនៅក្នុងគោលការណ៍ណែនាំអំពីការកសាងផែនការសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### ឃ) ក្រសួង និងស្ថាប័នពាក់ព័ន្ធនៅក្នុងវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

- កសាងផែនការសកម្មភាពប្រែប្រួលអាកាសធាតុដែលផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រវិស័យពាក់ព័ន្ធ និង NSDP ស្របតាមគោលការណ៍ណែនាំពី NCSD
- ធានាឲ្យមានសមាហរណកម្មជាបណ្តើរៗនៃសកម្មភាពប្រែប្រួលអាកាសធាតុនៅក្នុងកម្មវិធី/ផែនការសកម្មភាពសំខាន់ៗតាមវិស័យរបស់ខ្លួន
- បង្កើតនីតិវិធីនិងស្តង់ដារច្បាស់លាស់សម្រាប់ជ្រើសយកសកម្មភាព/គម្រោងនានានៅក្នុងដំណាក់កាលបង្កើតនិងកំណត់អត្តសញ្ញាណគម្រោង/សកម្មភាពដែលរងឥទ្ធិពលពីការប្រែប្រួលអាកាសធាតុ។ គិតបញ្ចូលថ្លៃចំណាយទៅក្នុងផែនការ និងការលើកថវិកាសម្រាប់សកម្មភាពទាំងនេះ
- បង្កើតរចនាសម្ព័ន្ធស្ថាប័ននៅក្នុងក្រសួងដើម្បីអនុវត្តន៍ និងតាមដានផែនការសកម្មភាពប្រែប្រួលអាកាសធាតុ( ជនបង្គោល ឬ ក្រុមការងារ ) និងផ្តល់ការគាំទ្រដល់នាយកដ្ឋានពាក់ព័ន្ធនានាអំពីបញ្ហាប្រែប្រួលអាកាសធាតុ
- ក្រោមភាពជាដៃគូជាមួយ NCSD និង MEF បានធ្វើការវិភាគនិងវាយតម្លៃថ្លៃចំណាយ-ផលចំណេញនៃសកម្មភាពដែលពាក់ព័ន្ធនឹងអាកាសធាតុ និងកំណត់សកម្មភាពដែលមានប្រសិទ្ធភាពខ្ពស់បំផុតខាងការចំណាយ
- សហប្រតិបត្តិការជាមួយក្រសួង និងស្ថាប័នផ្សេងទៀតទៅតាមអាណត្តិរបស់ខ្លួន ក្នុងពេលចាំបាច់ត្រូវរួមបញ្ចូលវិធានការឆ្លើយតបនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ

- សហប្រតិបត្តិការជាមួយ NCSD ដើម្បីកៀរគរធនធានសម្រាប់សកម្មភាពនានាដែលទាក់ទងនឹងអាកាសធាតុដែលរួមទាំងការកំណត់អត្តសញ្ញាណប្រភព និងគំរូនៃការផ្តល់មូលនិធិដែលមានសក្តានុពល។

ង ) ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការស្តារនិងអភិវឌ្ឍន៍កម្ពុជា ( CDC/CRDB)

- ក្រោមកិច្ចសហប្រតិបត្តិការជាមួយ NCSD ត្រូវធ្វើការកែលម្អវិធីតាមដានការប្រែប្រួលអាកាសធាតុនៅក្នុងកម្រងទិន្នន័យ ODA និងផ្តល់វគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធដល់ដៃគូអភិវឌ្ឍន៍
- រួមបញ្ចូល NCSD នៅក្នុងការពិនិត្យសេចក្តីព្រាងយុទ្ធសាស្ត្រដៃគូអភិវឌ្ឍន៍សម្រាប់ប្រទេសកម្ពុជាដើម្បីធានាថាកម្មវិធីនានាដែលទាក់ទងនឹងអាកាសធាតុត្រូវបានកំណត់អត្តសញ្ញាណតាំងពីដំណាក់កាលដើមដំបូងសម្រាប់ការរៀបចំឲ្យបានសមស្រប។

ច ) លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនិងរដ្ឋបាលក្រោមជាតិ

- រួមបញ្ចូលអាកាសធាតុទៅក្នុងគោលការណ៍ណែនាំសម្រាប់កសាងផែនការនិងការលើកថវិកាសម្រាប់មូលនិធិឃុំ-សង្កាត់ និងមូលនិធិស្រុក-ក្រុង ដោយផ្អែកតាមមេរៀនដែលទទួលបានពីការអនុវត្តសាកល្បងដែលមានស្រាប់
- រួមបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងអាទិភាពនានានិងនីតិវិធីកសាងផែនការ/ការអនុវត្តសម្រាប់មូលនិធិវិនិយោគនៅថ្នាក់ក្រោមជាតិ
- ក្រោមកិច្ចសហប្រតិបត្តិការជាមួយ NCSD ត្រូវបង្កើតវិធីតាមដានអាកាសធាតុសម្រាប់ការចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ តាមរយៈ CSF, DMF និង SNIF (ស្របតាមវិធីសាស្ត្រដែលបានគ្រោងទុកសម្រាប់ កម្រងទិន្នន័យ ODA និងថវិកាជាតិ)
- ក្រោមកិច្ចសហប្រតិបត្តិការជាមួយ NCSD ត្រូវគូសបញ្ជាក់អំពីការទទួលខុសត្រូវដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ នៅលំដាប់ថ្នាក់ខុសៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ( ខេត្ត ស្រុក ឃុំ )
- អភិវឌ្ឍន៍សមត្ថភាពខាងការប្រែប្រួលអាកាសធាតុនៅក្នុងអង្គភាពគាំទ្របច្ចេកទេសសម្រាប់យន្តការរដ្ឋបាលនៅថ្នាក់ក្រោមជាតិ នៅថ្នាក់ស្រុក និងខេត្ត។

ឆ ) ដៃគូអភិវឌ្ឍន៍

- ផ្តល់ហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុថ្មី និងបន្ថែមស្របជាមួយការប្តេជ្ញានៅក្រោមអនុសញ្ញា UNFCCC ប៉ុន្តែត្រូវធានាផងដែរថាគម្រោងODA ដូចមានកន្លងមក "**សកម្មភាពវៃឆ្លាតខាងកាសធាតុ**"
- នៅក្នុងដំណាក់កាលយុទ្ធសាស្ត្រតាមប្រទេស ត្រូវធានាថាមានការពិគ្រោះយោបល់ជាមួយ NCSD អំពីអាទិភាព និងកម្មវិធីនានាដែលបានស្នើឡើងដើម្បីឲ្យអន្តរាគមន៍នានាដែលពាក់ព័ន្ធនឹងអាកាសធាតុ ( ODA ពីមុនមក និងហិរញ្ញវត្ថុអាកាសធាតុបន្ថែម ) អាចកំណត់បានតាំងពីដំណាក់កាលដើមដំបូង និងបានបន្សុីគ្នាជាមួយផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា (CCCSP)

- ចំពោះគម្រោងនានាដែលបានកំណត់អត្តសញ្ញាណថាពាក់ព័ន្ធនឹងអាកាសធាតុត្រូវធានាថាបានទទួលយោបល់បច្ចេកទេសពី NCSD / និងឬក្រុមការងារបច្ចេកទេសអាកាសធាតុតាំងពីនៅក្នុងដំណាក់កាលបង្កើតគម្រោងនៅក្នុងក្រសួងពាក់ព័ន្ធដែលរួមទាំងអំពីស្តង់ដារពង្រឹងភាពធន់នឹងអាកាសធាតុដែលពាក់ព័ន្ធ ឬ លក្ខខណ្ឌចាំបាច់ផ្សេងទៀតនិងរួមបញ្ចូលថ្លៃចំណាយ និងធាតុចូលពាក់ព័ន្ធនានានៅក្នុងថវិកាគម្រោង
- ចូលរួមនៅក្នុងយន្តការរដ្ឋាភិបាល-ម្ចាស់ជំនួយសម្រាប់សម្របសម្រួលការប្រែប្រួលអាកាសធាតុចែករំលែកព័ត៌មាន និងស្វែងរកយោបល់តបអំពីកម្មវិធីដែលពាក់ព័ន្ធនឹងអាកាសធាតុដែលមានក្នុងពេលខាងមុខបន្សុីគ្នាជាមួយអាទិភាពជាតិដូចដែលបានកំណត់នៅក្នុង CCCSP និងផែនការនានាដែលពាក់ព័ន្ធ និងធានាថាគម្រោងដែលបានទទួលមូលនិធិគាំទ្រអាចរួមចំណែកទៅក្នុងក្របខ័ណ្ឌតាមដាននិងវាយតម្លៃរបស់ជាតិ។ ក្នុងករណីអាចធ្វើបានត្រូវពិចារណាប្រមូលផ្តុំធនធានជាមួយដៃគូដែលមានចំណាប់អារម្មណ៍ផ្សេងទៀតដើម្បីកាត់បន្ថយថ្លៃចំណាយអន្តរការ
- រាយការណ៍ជាលក្ខណៈប្រព័ន្ធអំពីការពាក់ព័ន្ធនៃអាកាសធាតុនៅក្នុងសំណុំរឿងរបស់ខ្លួនតាមរយៈវិធីតាមដានអាកាសធាតុដូចមានក្នុងកម្រងទិន្នន័យ ODA របស់ CDC/CRDB
- នៅពេលផ្តល់ការគាំទ្រតាមវិស័យ ឬ ការគាំទ្រជាថវិកាទូទៅ ត្រូវរួមបញ្ចូលការប្រែប្រួលអាកាសធាតុនៅក្នុងក្របខ័ណ្ឌលទ្ធផល (ស្របគ្នាជាមួយ CCCSP និងក្របខ័ណ្ឌតាមដាននិងវាយតម្លៃនៅថ្នាក់ជាតិសម្រាប់ការប្រែប្រួលអាកាសធាតុ) និងផ្តល់ហិរញ្ញវត្ថុអាកាសធាតុដែលគាំទ្រដល់គោលបំណងទាំងនេះ
- បង្កើនវត្តមានហិរញ្ញវត្ថុអាកាសធាតុនៅកម្រិតសមស្រប តាមរយៈ CSF, DMF និង SNIF អនុលោមតាមកម្រិតនៃសមាហរណកម្មការប្រែប្រួលអាកាសធាតុក្នុងនីតិវិធីកសាងផែនការនិងការលើកថវិកាសម្រាប់មូលនិធិទាំងនេះ
- ក្នុងករណីពាក់ព័ន្ធត្រូវរួមបញ្ចូលអន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាពដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុទាំងនៅកម្រិតបុគ្គល(ការអភិវឌ្ឍនជំនាញ) និងនៅកម្រិតស្ថាប័ន(និយមន័យស្តង់ដារដែលអាចអនុវត្តបានគោលការណ៍ និងនីតិវិធីការស្រាវជ្រាវនិងការអភិវឌ្ឍ)។

ឧបត្ថម្ភ និងគាំទ្រដោយ

CAMBODIA CLIMATE CHANGE ALLIANCE

Implemented by: Supported by:

Ministry of Environment

European Union

Empowered lives. Resilient nations.

SWEDEN